**ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ**

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ( **ASPIRE** )

# គោលការណ៍ណែនាំ
# ការជ្រើសរើសនិងចងក្រង ក្រុមកសិករសិក្សាខ្នាតតូច
## Smallholder Learning Group (SLG)



រូបភាព អង្គការឃែរអន្តរជាតិនៅកម្ពុជា

**រៀបចំដោយ :** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយ:** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០១៧

# មាតិកា

ទំព័រ


**មាតិកា** ........ 2

**អារម្ភកថា** ........ 2

**សេចក្តីថ្លែងអំណរគុណ** ........ 3

**១. សេចក្តីផ្តើម** ........ 2

**២. គោលបំណង និងគោលដៅ** ........ 2

**៣. វិធីសាស្ត្រចងក្រងក្រុមកសិករសិក្សាខ្នាតតូច** ........ 3

**៤. ជំហានអនុវត្តន៍** ........ 4

**ជំហានទី១: ការប្រជុំផ្សព្វផ្សាយគោលបំណង និងគោលដៅរបស់ កម្មវិធី ឬគម្រោងតាមភូមិ ឃុំគោលដៅ** ........ 4

**ជំហានទី២: ការជ្រើសរើសកសិករ និងការរៀបចំក្រុមកសិករសិក្សាខ្នាតតូច** ........ 7

**ជំហានទី ៣: ការធ្វើចំណាត់ថ្នាក់ទ្រព្យធនរបស់ ក្រុមកសិករ** ........ 8

តារាងទី ៣.១. តារាងធ្វើចំណាត់ថ្នាក់ទ្រព្យធន ........ 9

តារាងទី៣.២. តារាងព័ត៌មានលម្អិតពីកសិករដែលបានចូលរួមក្នុងក្រុមសិក្សាខ្នាតតូច ........ 7

តារាង ៣.៣. ឈ្មោះក្រុមកសិករសិក្សាខ្នាតតូច ........ 8

**ជំហានទី ៤: ការរៀបចំរចនាសម្ព័ន្ធក្រុម លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងកសិករសិក្សាខ្នាតតូច** ........ 10

**លក្ខន្តិកៈរបស់ក្រុមកសិករសិក្សាខ្នាតតូច** ........ 19

**បទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមកសិករសិក្សាខ្នាតតូច** ........ 25

**ជំហានទី ៥: យន្តការស្មារតីរបស់ក្រុមកសិករសិក្សាខ្នាតតូច** ........ 27

## អារម្ភកថា

កសិកម្មខ្នាតតូច គឺបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមចំណែកជម្រុញកំណើនសេដ្ឋកិច្ចគ្រួសារកសិករនៅទីជនបទ ឬអាចហៅម្យ៉ាងទៀតបានថា កសិកកម្មខ្នាតតូច គឺជាម៉ាស៊ីនក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ច ។ ការប្រមូលផ្តុំគ្នាជាក្រុម នាំឲ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍គ្នា នាំឲ្យមានការចែករំលែកគ្នានូវបច្ចេកទេស ទេព្យកោសល្យ ឬចំណេះដឹង គឺជាកំលាំងចលកមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាននៅក្នុងការដោះស្រាយបញ្ហាដែលកើតមាន ស្វែងរកនូវគន្លឹះ ឬវិធីសាស្រ្តល្អៗសម្រាប់ដោះស្រាយនូវបញ្ហានានា និងដើម្បីបញ្ចៀសបាននូវការខាតបង់ពេលវេលា និងថវិកា។ មិនត្រឹមតែប៉ុណ្ណោះ ការផ្លាស់ប្តូរនូវបទពិសោធន៍ និងការចែករំលែកទាំងនេះ គឺបានចូលរួមយ៉ាងសកម្មនៅក្នុង ការជម្រុញឲ្យមានកំណើននៃការអនុវត្តន៍ផលិតកម្មកសិកម្ម ជម្រុញឲ្យមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារកសិករ សម្រួលដល់កសិករក្នុងការសម្របខ្លួនតាមស្ថានភាពវិវត្ត នៃសាកលភាវូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ ក៏ដូចជាចូលរួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែនាពេលបច្ចុប្បន្ន កសិករនៅមិនទាន់មានការប្រមូលផ្តុំគ្នាជាក្រុមក្នុងការផលិត មិនមានការចងក្រងគ្នាជាក្រុម មិនមានអំណាចតថ្លៃលើទីផ្សារផលិតផលកសិកម្មរបស់ខ្លួន មិនមានបច្ចេកវិទ្យាកសិកម្មគ្រប់គ្រាន់ និងរឹតតែមិនអាចសម្របខ្លួនបានទៀតជាមួយនឹងការប្រែប្រួលអាការធាតុ ឬកសិករខ្លះបានបោះបង់ចោលនូវមុខរបរកសិកម្ម និងធ្វើចំណាកស្រុកច្រើន ជាពិសេសយុវជនដែលជាកំលាំងស្នូលក្នុងការបន្តវេនកសិកម្មទៅថ្ងៃមុខ។ ដោយមើលឃើញនូវសារប្រយោជន៍ពីកសិករខ្នាតតូច និងការប្រឈមរបស់កសិករខ្នាតតូចទាំងនេះទើប រាជរដ្ឋាភិបាលកម្ពុជា ដែលមានអគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាសេនាធិការ បានសហការជាមួយ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) រៀបចំចងក្រងឲ្យមានជា គោលការណ៍ណែនាំ ស្តីពី **ចងក្រងក្រុមកសិករសិក្សាខ្នាតតូច** នេះឡើង។ គោលការណ៍ណែនាំនេះ ជាឯកសារជំនួយ ស្មារតីមួយយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ភ្នាក់ងារកសិកម្មក្នុងការទូទាំងប្រទេសយកទៅប្រើប្រាស់ ជាប្រយោជន៍ក្នុងការចងក្រងក្រុមកសិករសិក្សាខ្នាតតូច ពីព្រោះកូនសៀវភៅនេះ បានបង្ហាញនូវគន្លឹះសំខាន់ៗជាច្រើនសម្រាប់ជាប្រទីបបំភ្លឺផ្លូវក្នុងការចងក្រងក្រុមកសិករសិក្សាខ្នាតតូចដែលអាចឲ្យមានក្រុមកសិករសិក្សាខ្នាតតូច ទទួលបាននូវបច្ចេកវិទ្យា បច្ចេកទេសទាន់ពេលវេលា និងគ្រប់គ្រាន់ដែលអាចឲ្យកសិករ ក្រុមកសិករសិក្សាខ្នាតតូចឬសហគមន៍ កសិកម្មទទួលបាន និងយកទៅអនុវត្តបាន និងមានដំណើរការប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងមាននិរន្តរភាព។

រាជធានីភ្នំពេញ,ថ្ងៃទី...............ខែ.............ឆ្នាំ២០.....

អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម និង

ជាប្រធានគ្រប់គ្រងកម្មវិធីផ្នែកផ្សព្វផ្សាយកសិកម្ម

បច្ចេកវិទ្យា និងការស្រាវជ្រាវ

**លោកបណ្ឌិត ម៉ាក់ សឿន**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) ដែលបានផ្តល់ថវិកាដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានគោលបំណងកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធី គឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ ផ្សព្វផ្សាយកសិកម្ម។

គោលការណ៍ណែនាំ "**ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច**" នេះជា សមិទ្ធិផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរការរៀបចំសៀវភៅ នេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃអគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

ដើម្បីកត់ត្រាទុកនូវវិភាគទានដ៏មានតម្លៃទាំងនេះយើងខ្ញុំសូមថ្លែងអំណាគុណចំពោះក្រុមការងាររៀបចំសៀវភៅដែលមាន លោកបណ្ឌិត ម៉ាក់ សឿន លោកបណ្ឌិត ម៉ៅ មីនា លោក ចាយ គង់គ្រុយ លោក ខៀន សុវណ្ណារា លោក សាយ តុម លោក ទី គៀង ដែលបានខិតខំ ស្រាវជ្រាវ ចងក្រង សៀវភៅនេះលេចជារូបរាងឡើងប្រកបដោយអត្ថប្រយោជន៍សម្រាប់ បណ្តុះបណ្តាលមន្ត្រី ដើម្បីឲ្យគេមានទំនុកចិត្តក្នុងការផ្តល់បច្ចេកទេសបន្តដល់ក្រុមកសិករ នឹងដើម្បីបង្កើននូវបរិយាកាស ដែលអាចឲ្យមានការចូលរួមអនុវត្តសកម្មភាពរបស់កម្មវិធីពីសហគមន៍ ការចូលរួមកាត់បន្ថយ ភាពក្រីក្រ និងបង្កើនប្រាក់ចំណូលរបស់កសិករខ្នាតតូច ក្រីក្រ និងងាយរងគ្រោះក្នុងប្រទេសកម្ពុជា ។

## ១. សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុជាបញ្ហាសាកល ដែលកើតមានឡើងយ៉ាងច្បាស់ និងមានឥទ្ធិពលលើផលិតកម្មស្បៀងអាហារនៅក្នុងបណ្តាប្រទេសមួយចំនួនលើសាកលលោក ដោយការកើតមានឡើង៖ ការកើនឡើងកំដៅ ទឹកជំនន់ រាំងស្ងួត ភ្លៀងមិនទៀងទាត់ សត្វល្អិត ជម្ងឺ ការកើនឡើងកំពស់ទឹកប្រៃហូរចូលដីស្រែ ចំការ។ល។ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុរួចមកហើយតាមរយៈការកើតឡើងពីភាពប្រក្រតីនៃអាកាសធាតុ ដូចជាមានព្រឹត្តិការណ៍ទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិត និងជម្ងឺបំផ្លាញ ខ្យល់ព្យុះ ការកើនឡើងកំពស់ទឹកសមុទ្រ ដែលបណ្តាលឲ្យមានផលិតភាពកសិកម្មទាប និងមានផលប៉ះពាល់ដល់សន្តិសុខស្បៀង និងភាពក្រីក្រ ដោយមានឆ្នេរសមុទ្រវែងរហូតដល់ ៤៣៥គីឡូម៉ែត្រ និងមានរយៈកំពស់ទាប ផ្ទៃដីវាលទំនាបតាមអាងទន្លេគង្គក្រោម តំបន់ទន្លេសាប ហើយមានប្រជាពលរដ្ឋរស់នៅច្រើន និងមានសកម្មភាពសេដ្ឋកិច្ចពឹងផ្អែកលើមុខរបរកសិកម្ម ធនធានជលផល ព្រៃឈើ និងធនធានធម្មជាតិហើយមានផ្ទៃដីស្រែទំនាបពឹងដោយរបបទឹកភ្លៀង ប្រមាណជាង ២.៥លានហិកតា។

វិស័យកសិកម្មបានទទួលរងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តែវិស័យកសិកម្មក៏បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបន្សាំ បង្កើនភាពធន់ និងបន្ធូរបន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដើម្បីធានាប្រព័ន្ធផលិត ចែកចាយ និងផ្គត់ផ្គង់ស្បៀង មាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការប្រើប្រាស់ និងការអនុវត្តល្អប្រសើរនៃបច្ចេកវិទ្យាកសិកម្ម៖ ពូជដំណាំ ពូជសត្វ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះប្រពលវប្បកម្មដំណាំ សត្វ ច្បារដំណាំគ្រួសារ កសិកម្មអភិរក្ស ប្រព័ន្ធដំណាំស្បៀង និងថាមពលចម្រុះ ការប្រើប្រាស់ថាមពលទាបនៃប្រព័ន្ធវារីវប្បកម្ម ប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដី និងទឹកមាននិរន្តរភាព និងក្សេត្រ រុក្ខកម្ម។ល។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ ជាកម្មវិធីជាតិមួយ មានគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីនេះមានគោលដៅ លើកកម្ពស់គំរូសេវាកសិកម្មដែលបានបង្កើតឡើង និងត្រូវអនុវត្តពីឆ្នាំ ២០១៥ ដល់ ២០២១ សម្រាប់ជួយកសិករខ្នាតតូចទូទៅ ដើម្បីដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច តាមរយៈបង្កើនប្រាក់ចំណូល និងភាពធន់ក្នុងមុខរបរកសិកម្ម។ សមាសភាពទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្មដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្ម។

គោលការណ៍ណែនាំសម្រាប់ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច ត្រូវរៀបចំឡើងសម្រាប់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មជួយរៀបចំក្រុមកសិករដើម្បីចេះដោះស្រាយបញ្ហា ឧបសគ្គ ដែលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ លទ្ធភាព សមត្ថភាព ភាពបន្សាំ របស់កសិករនៅមូលដ្ឋាន និងតម្រូវការបច្ចេកទេសកសិកម្មនានាសម្រាប់បង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍កសិករ។

## ២. គោលបំណង និងគោលដៅ

ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច នៅតាមភូមិ ឃុំគោលដៅ ដើម្បីលើកកម្ពស់ការយល់ដឹង និងបង្កើនសមត្ថភាពរបស់កសិករ ក្រុមកសិករនិងសហគមន៍កសិកម្មក្នុងការបង្កើនផលិតភាព គុណភាព សុវត្ថិភាពផលិតផលកសិកម្ម បង្កើនប្រាក់ចំណូល និងជីវភាពរស់នៅ ព្រមទាំងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

តាមរយៈការផ្ទេរបច្ចេកវិទ្យាកសិកម្ម ដំណោះស្រាយបញ្ហា តម្រូវការបច្ចេកទេសកសិកម្មវៃឆ្លាត ការគ្រប់គ្រងធនធានផលិតកម្មកសិកម្ម (មានទុន ធាតុចូល ទឹក និងដី) ទីផ្សារ និងជម្រើសនានា។

**គោលបំណង** ជម្រុញឲ្យមានការចូលរួមរបស់កសិករ បង្កភាពងាយស្រួលក្នុងការទំនាក់ទំនង ការផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ការផ្លាស់ប្តូរបទពិសោធន៍ បង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលគ្រួសារ ដើម្បីឲ្យកសិករក្លាយជាសហគ្រិនកសិកម្ម តាមរយៈក្រុមកសិករសិក្សាខ្នាតតូច។

គោលការណ៍ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច មានគោលដៅលម្អិតដូចខាងក្រោម៖

- ណែនាំដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងក្រុមកសិករ ក្នុងការបង្កើតក្រុមកសិករសិក្សាខ្នាតតូច ជាក្រុមផលិតកម្មស្បៀង ជាក្រុមកសិករអាជីពក្នុងការធ្វើអាជីវកម្មកសិកម្ម និងសហគ្រាសកសិកម្ម
- កំណត់អាទិភាពតម្រូវការ ជម្រើសបច្ចេកទេស បច្ចេកវិទ្យា និងការកសាងសមត្ថភាពរបស់កសិករ ដើម្បីបន្សាំ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅតាមតំបន់គោលដៅរបស់កម្មវិធី
- ផ្តល់តម្រូវការបច្ចេកវិទ្យាដល់កសិករខ្នាតតូច ក្រុមកសិករ និងសហគមន៍កសិកម្ម ដើម្បីបង្កើនផលិតកម្មកសិកម្ម តាមស្តង់ដាទីផ្សារ និងការប្រកួតប្រជែង
- លើកកម្ពស់ការយល់ដឹង និងផ្តល់អំណាច ដល់កសិករសិក្សាខ្នាតតូច សហគមន៍កសិកម្ម អំពីរបៀបគ្រប់គ្រង និងដំណើរការអាជីវកម្មកសិកម្ម ប្រកបដោយនិរន្តរភាព។

# ៣. វិធីសាស្ត្រចងក្រងក្រុមកសិករសិក្សាខ្នាតតូច

ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច គឺធ្វើឡើងក្នុងកម្រិតភូមិ ដោយមានការចូលរួមពីកសិករស្ម័គ្រទាំងអស់មានបុរសនិងស្ត្រីដែលនៅក្នុងភូមិ និងធ្វើការជ្រើសរើសកសិករដោយឲ្យកសិករទាំងអស់ចូលរួមអនុវត្តចំណាត់ថ្នាក់ ទ្រព្យធន និងប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករ របស់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ល។

អ្នកចូលរួមក្នុងក្រុមកសិករសិក្សាខ្នាតតូចអាចជ្រើសរើស ជាកសិករដែលចាប់អារម្មណ៍ចូលរួមក្នុងកម្មវិធីដែលមកពី គ្រួសារកសិករខ្នាតតូច ក្រុមកសិករ ឬសហគមន៍កសិកម្ម។ល។

ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច ទៅតាមជំហានអនុវត្តនីមួយៗ៖

១. ការប្រជុំផ្សព្វផ្សាយគោលបំណង និងគោលដៅរបស់កម្មវិធី ឬគម្រោង (ឧទាហរណ៍ៈ កម្មវិធី ASPIRE) តាមភូមិ ឃុំគោលដៅ។

២. ការប្រជុំជ្រើសរើសក្រុមកសិករ ពី ២៥ ទៅ ៣០នាក់ ចូលរួមក្រុមកសិករសិក្សាខ្នាតតូច។ ការចងក្រងក្រុមកសិករសិក្សាខ្នាតតូចដោយប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រចូលរួម។

៣. ធ្វើការវិភាគលើចំណាត់ថ្នាក់ទ្រព្យធនរបស់កសិករដើម្បីរៀបចំក្រុម ទៅតាមការចាប់អារម្មណ៍តាមក្រុមមាន ក្រុមក្រ ១ ក្រ២ ជាក្រុមផលិតកម្មស្បៀងគ្រួសារ (ផលិតសម្រាប់ហូប និងលក់ដូរ) កសិករមធ្យម និងគ្រាន់បើ ជាក្រុមកសិករអាជីពធ្វើអាជីវកម្ម (ផលិតសម្រាប់លក់)។

៤. រៀបចំរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង រៀបចំលក្ខន្តិកៈនិងបទបញ្ញាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច ។

៥. យន្តការស្មារតីរបស់ក្រុមកសិករសិក្សាខ្នាតតូច។

## ៤. ជំហានអនុវត្តន៍

### ជំហានទី១: ការប្រជុំផ្សព្វផ្សាយគោលបំណង និងគោលដៅរបស់ កម្មវិធី ឬគម្រោងតាមភូមិ ឃុំគោលដៅ

**គោលបំណង** ដើម្បីឲ្យកសិករយល់ដឹងពីគោលបំណង និងគោលដៅរបស់កម្មវិធី ឬគម្រោង និងកសិករចាប់អារម្មណ៍ចូលរួមក្នុងការអនុវត្តន៍កម្មវិធី ឬគម្រោងនៅក្នុងភូមិ ឃុំ គោលដៅ។ ការប្រជុំផ្សព្វផ្សាយនេះមានគោលដៅលម្អិត៖

- ដើម្បីឲ្យកសិករយល់ដឹងពី អ្នកគាំទ្រ និងដៃគូផ្តល់ជំនួយដល់កម្មវិធី ឬគម្រោង
- យល់ដឹងពីសកម្មភាព រយៈពេលអនុវត្ត និងឥទ្ធិពលរបស់កម្មវិធី ឬគម្រោងដែលមានផលប្រយោជន៍ដល់កសិករ ក្រុមកសិករ និងសហគមន៍កសិកម្ម នៅភូមិ ឃុំគោលដៅ
- ដើម្បីឲ្យកសិករយល់ដឹងពី លក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ ចំណាប់អារម្មណ៍ចូលរួម និងស្ម័គ្រចិត្តចូលរួមក្នុងក្រុមកសិករសិក្សាខ្នាតតូច។

**លទ្ធផលរំពឹងទុក**:

- កសិករចូលរួមបានយល់ដឹង និងមានការចាប់អារម្មណ៍ ចូលរួមក្នុងកម្មវិធី ឬគម្រោង
- កំណត់បានកសិករចូលរួមក្នុងក្រុមកសិករសិក្សាខ្នាតតូច ពី ២៥ ទៅ ៣០នាក់។

**អ្នកចូលរួម** :

- អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ គណៈកម្មាការអភិវឌ្ឍន៍ភូមិ គណៈកម្មាការទទួលបន្ទុក ស្ត្រីនិងកុមារឃុំ និងកសិករចាប់អារម្មណ៍ស្ម័គ្រចិត្តចូលរួម។

**សំភារៈ**:

- ក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្រដាស ស្កុត កន្ត្រៃ ។ល។
- ឯកសារ ព្រឹត្តប័ត្រ ខិតប័ណ្ណ របស់កម្មវិធី ឬគម្រោង (ឧ. កម្មវិធី ASPIRE)

**រយៈពេល**: ២ ម៉ោង

**ទីកន្លែង**: ក្នុងភូមិ

**អ្នកសម្របសម្រួល**: មន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ ។

**ដំណើរការអនុវត្ត**:

អ្នកសម្របសម្រួល ត្រូវ៖

- ណែនាំពីគោលបំណងនៃការប្រជុំផ្សព្វផ្សាយ
- បង្ហាញគោលបំណង គោលដៅ សកម្មភាព និងផលប្រយោជន៍ពីការអនុវត្តកម្មវិធី ឬគម្រោង នៅភូមិ ឃុំគោលដៅ
- បង្ហាញពីលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ ចំណាប់អារម្មណ៍ចូលរួម និងស្ម័គ្រចិត្តចូលរួមក្នុងក្រុមកសិករ សិក្សាខ្នាតតូច សកម្មភាពរបស់កម្មវិធី ឬគម្រោងមានៈ ឧទា.កម្មវិធី ASPIRE
- កំណត់ជ្រើសរើសកសិករ និងចងកងក្រុមកសិករសិក្សាខ្នាតតូច

- ការវាយតម្លៃពីតម្រូវការរបស់កសិករ ក្រុមកសិករ សហគមន៍កសិកម្ម នៅក្នុងភូមិ ឃុំគោលដៅ
- ចូលរួមក្នុងសកម្មភាពរបស់កម្មវិធី មានៈ សាលារៀនស្រែកសិករ ការធ្វើបង្ហាញគំរូ ទិវាស្រែ វេទិកានានា ការធ្វើអាជីវកម្មកសិកម្មក្នុងគ្រួសារ ឬក្រុម (ក្រុមផលិត ក្រុមលក់ដូរ ក្រុមសន្សំ...។ល។)
- ប្រើប្រាស់សេវារបស់ក្រុមកសិករ ឬសហគមន៍កសិកម្ម និងដៃគូអនុវត្តកម្មវិធី។

អ្នកសម្របសម្រួលត្រូវបង្ហាញនិងណែនាំ ពីលក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យសំខាន់ៗចូលរួមក្នុងកម្មវិធីរួមមានៈ

- មានទីលំនៅជាក់លាក់ក្នុងភូមិ និងមិនធ្វើចំណាកស្រុក
- ស្ម័គ្រចិត្ត ឧស្សាព្យាយាម និងគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារកសិកម្ម
- មានពេលវេលា ចូលរួមជាមួយកម្មវិធី ឬគម្រោង
- មានឆន្ទៈពង្រីកចំណេះដឹងតាមរយៈ ការបណ្តុះបណ្តាល ប្រជុំនិងព្រឹត្តិការណ៍ផ្សេងៗរបស់កម្មវិធី ឬគម្រោង
- មានឆន្ទៈ ចូលរួមផ្ទេរបច្ចេកទេសកសិកម្ម ចែករំលែកបទពិសោធន៍ចំណេះដឹងដល់កសិករផ្សេងៗទៀត
- ជាកសិករមានភាពងាយទទួលរងគ្រោះក្នុងការដាំដំណាំ ការចិញ្ចឹមសត្វដោយមូលហេតុបម្រែបម្រួលអាកាសធាតុ និងបញ្ហាទីផ្សារកសិផល
- កសិករមានប័ណ្ណក្រី ក្រ១ និង ក្រ២ (មានដីធ្វើសួនបន្លែ ចិញ្ចឹមសត្វ)
- កសិករជាសមាជិកក្រុមកសិករ និងសហគមន៍កសិកម្មដែលមានស្រាប់នៅក្នុងភូមិ ឃុំគោលដៅ
- មានទំនាក់ទំនងល្អជាមួយកសិករដ៏ទៃទៀតក្នុងភូមិ និងមានសុជីវធម៌ល្អ
- ផ្តល់អាទិភាពដល់ស្ត្រីជាមេគ្រួសារ (យ៉ាងតិច ៣០%)
- មិនប្រកាន់ពូជសាសន៍ និន្នាការនយោបាយ។

# ជំហានទី២: ការជ្រើសរើសកសិករ និងការរៀបចំ ក្រុមកសិករសិក្សាខ្នាតតូច

**គោលបំណង ៖**

ការជ្រើសរើសកសិករ និងចងក្រងក្រុមកសិករសិក្សាខ្នាតតូចគឺ ដើម្បីចូលរួមអនុវត្តកម្មវិធី ឬគម្រោង។ គោលដៅសំខាន់ៗមាន:

- ជ្រើសរើសបានកសិករស្ម័គ្រចិត្ត ចំនួន ពី២៥ ទៅ៣០នាក់ ដើម្បីចូលរួមក្នុងក្រុមកសិករសិក្សាខ្នាតតូច របស់កម្មវិធី ឬគម្រោង។

**លទ្ធផលរំពឹងទុក ៖**

- បានរៀបចំក្រុមកសិករសិក្សាខ្នាតតូចដែលមានកសិករ ស្ម័គ្រចិត្ត ពី២៥ ទៅ៣០នាក់ សម្រាប់ចូលរួមអនុវត្ត កម្មវិធី ឬគម្រោង មានប្រសិទ្ធិភាព និងតម្លាភាព។

**អ្នកចូលរួម** :

- កសិករចាប់អារម្មណ៍ និងស្ម័គ្រចិត្ត និងមានការចូលរួមគាំទ្រពី អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ ឬ គណៈកម្មការ ទទួលបន្ទុក ស្ត្រី និងកុមារឃុំ (CWCC)។

**សម្ភារ**:

- ក្រដាសផ្ទាំងធំ ហ្វឹតសរសេរក្រដាស ស្កុត កន្ត្រៃ សៀវភៅសរសេរ និងប៊ិច។

**រយៈពេល**: ៤ ម៉ោង

**ទីកន្លែង**: ក្នុងភូមិ

**អ្នកសម្របសម្រួល**: មន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ ។

**ដំណើរការអនុវត្ត**:

១. អ្នកសម្របសម្រួលណែនាំបង្ហាញពីគោលបំណងនៃការរៀបចំក្រុមដែលមានកសិករស្ម័គ្រចិត្តចំនួន២៥ ទៅ៣០នាក់។

២. អ្នកសម្របសម្រួលត្រូវដឹកនាំការពិភាក្សានិងបង្ហាញ៖

- អំពីសារៈសំខាន់នៃការចងក្រងក្រុម
- ពន្យល់អត្ថន័យនៃពាក្យក្រុមកសិករៈ
  - មានគំនិត និងចំណាប់អារម្មណ៍ដូចគ្នាឬប្រហាក់ប្រហែលគ្នា
  - គោលបំណងរួម
  - ស្ម័គ្រចិត្តរួមសហការ ការងារជាមួយគ្នា
  - ភាពស្មោះត្រង់ តស៊ូ និងទទួលខុសត្រូវជាមួយគ្នា
  - ត្រៀមខ្លួនរួចជាស្រេចក្នុងការរៀបចំដោយខ្លួនឯងនូវកិច្ចប្រជុំការធ្វើផែនការ សកម្មភាពរួមគ្នា
  - ត្រៀមខ្លួនក្នុងការជ្រើសរើស និងចូលរួមក្នុងគណៈកម្មាធិការគ្រប់គ្រងក្រុម
  - កសិករស្ម័គ្រចិត្តចូលរួមបង្កើត និងគោរពតាមបទបញ្ជាផ្ទៃក្នុងដែលបានបង្កើត
  - ស្ម័គ្រចិត្តចូលរួម និងទទួលផលប្រយោជន៍ជាមួយគ្នា។

- ពន្យល់អត្ថន័យនៃពាក្យ **គុណសម្បត្តិនៃ** "**ក្រុមកសិករ**" ដោយពិភាក្សាជាក្រុម និងបង្ហាញលទ្ធផលដែលក្រុមបានឯកភាព:
    - ទទួលបានផលចំណេញច្រើនជាងមុនតាមរយៈការធ្វើការងារជាក្រុម
    - ទទួល និងចែករំលែកពីគ្នាទៅវិញទៅមកនូវព័ត៌មាន បទពិសោធន៍ និងចំណេះដឹង
    - ជួយគ្នាទៅវិញទៅមក (ការប្រវាស់ដៃគ្នា)
    - ធនធានត្រូវបានការពារ និងប្រើប្រាស់ជាផលប្រយោជន៍របស់ក្រុម
    - មានប្រសិទ្ធភាពក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកផ្តល់សេវាកម្មគាំទ្រ៖ ស្ថាប័នផ្តល់ឥណទាន និង ការបណ្តុះបណ្តាលជាដើម...
    - តំណាងកសិករអាចមានឥទ្ធិពលកាន់តែខ្លាំងក្នុងការបញ្ចេញយោបល់ជាសម្លេងតែមួយ
    - សមាជិកសំខាន់ៗទាំងអស់អាចទទួលបានចំណេះដឹងក្នុងការដឹកនាំ
    - អត្តសញ្ញាណខាងវប្បធម៌ និងសកម្មភាពរបស់ពួកគាត់ត្រូវបានគេស្គាល់ និងរឹងមាំជាងមុន
    - ទំនាក់ទំនងនៅក្នុងសង្គមនឹងធ្វើឱ្យប្រសើរឡើងនូវបណ្តាញមុខរបររបស់សមាជិកក្រុម
- បង្ហាញលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ ចំណាប់អារម្មណ៍ចូលរួម និងស្ម័គ្រចិត្តចូលរួមក្នុងក្រុមកសិករ ដើម្បីជ្រើសរើសកសិករ ចំនួន ២៥ទៅ៣០នាក់។

# ជំហានទី ៣: ការធ្វើចំណាត់ថ្នាក់ទ្រព្យធនរបស់ក្រុមកសិករ

**គោលបំណង** ៖

ការធ្វើចំណាត់ទ្រព្យធនរបស់កសិករគឺ ដើម្បីបែងចែកក្រុមកសិករតាមចំណាត់ទ្រព្យធន និងតាមចំណាប់អារម្មណ៍ (ក្រុមក្រ ១ ក្រ២ ជាក្រុមផលិតកម្មស្បៀងគ្រួសារ ក្រុមផលិតសម្រាប់ហូប និងលក់ដូរ) ក្រុមកសិករមធ្យម និងគ្រាន់បើ ជាក្រុមកសិករអាជីពធ្វើអាជីវកម្ម (ផលិតសម្រាប់លក់)។

**លទ្ធផលរំពឹងទុក** ៖

- បានធ្វើចំណាត់ថ្នាក់និងបង្កើត ក្រុមផលិតកម្មស្បៀងគ្រួសារ ក្រុមផលិតសម្រាប់ហូប លក់ដូរ និងក្រុមកសិករអាជីពធ្វើអាជីវកម្ម (ផលិតសម្រាប់លក់)។

**អ្នកចូលរួម** :

- កសិករចាប់អារម្មណ៍ និងស្ម័គ្រចិត្ត និងមានការចូលរួមគាំទ្រពី អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ ឬ គណៈកម្មការទទួលបន្ទុក ស្ត្រី និងកុមារឃុំ (CWCC) និងមន្ត្រីផ្សព្វផ្សាយ ខេត្ត ស្រុក និងភ្នាក់ងារ ផ្សព្វផ្សាយឃុំ។

**សម្ភារ និងឧបករណ៍**:

- បញ្ជីសមាជិកគ្រួសារកសិករក្នុងភូមិ តាមស្ថានភាពជីវភាពគ្រួសារ (បើសិនមាន)
- ក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្រដាស ស្កុត កន្ត្រៃ សៀវភៅសរសេរ និងប៊ិច

**រយៈពេល**: ២ ម៉ោង

**ទីកន្លែង**: ក្នុងភូមិ

**អ្នកសម្របសម្រួល**: មន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ។

**ដំណើរការអនុវត្ត**:

- ជ្រើសរើសកសិករចូលរួមក្រុមដោយប្រើប្រាស់បញ្ជីស្ថានភាពជីវភាពគ្រួសារ
- ផ្ទៀងផ្ទាត់តាមតារាងចំណាត់ថ្នាក់ទ្រព្យធនដូចខាងក្រោម
- ប្រសិនបើគ្មានទិន្នន័យទាំងពីរខាងលើត្រូវធ្វើតារាងចំណាត់ថ្នាក់ទ្រព្យធនខាងក្រោម (តារាងទី៣.១)
- ពេលជ្រើសរើសកសិករតាមចំណាត់ថ្នាក់ទ្រព្យធនបានហើយត្រូវកត់ត្រា (តារាងទី៣.២)។

## ប្រើប្រាស់ឧបករណ៍ ការធ្វើចំណាត់ថ្នាក់ទ្រព្យធន

**តារាងទី ៣.១. តារាងធ្វើចំណាត់ថ្នាក់ទ្រព្យធន**

| ចំណាត់ថ្នាក់ទ្រព្យធន | គ្រួសារមធ្យម | គ្រួសារក្រ២ | គ្រួសារក្រ១ |
|---|---|---|---|
| ប្រភេទផ្ទះ | គ្រឿង សង្កសី ស៊ីប្រូ | ដំបូលសង្កសី ជញ្ជាំងស្លឹក | ដំបូលស្លឹក ជញ្ជាំងស្លឹក បិទដី |
| ដីស្រែ (ហត) | ១,៥-២ ហត | ០,៧-១ហត | តិចជាង ០,៣ ហត |
| ដីលំនៅដ្ឋាន | ០,៣-០,៤ ហត | ០,២-០,៣ ហត | តិចជាង ១០អា |
| ទ្រព្យសម្បត្តិ | គោយន្ត ម៉ាស៊ីនបូមទឹក ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបោកស្រូវ ម៉ូតូ ទូរទស្សន៍ | វិទ្យុ ម៉ូតូ ទូរទស្សន៍ កង់ | កង់ វិទ្យុ |
| ស្បៀង | សល់លក់ | ខ្វះ ១-២ខែ | ខ្វះ ២-៣ខែ |
| ចំនួនគោ ក្របី | ៤-៥ ក្បាល | ២-៣ ក្បាល | តិចជាង ២ក្បាល |
| ចំនួនជ្រូក | ២-៥ ក្បាល | ១-២ ក្បាល | គ្មាន |
| ចំនួនមាន់ | ១៥-២០ ក្បាល | ៥-១០ ក្បាល | ១-៥ ក្បាល |
| កំលាំងពលកម្មរកការងារក្រៅពីកសិកម្ម | កម្មការកាត់ដេរ | កម្មករសំណង់ ម៉ូតូឌុប | លក់កំលាំងពលកម្ម |
| ការប្រើប្រាស់ឥណទាន | | ឥណទានខ្នាតតូច (អត្រា ១០%) | សហគមន៍,ឈ្មួញ (អត្រា ១០%) |

**តារាងទី៣.២. តារាងព័ត៌មានលម្អិតពីកសិករដែលបានចូលរួមក្នុងក្រុមសិក្សាខ្នាតតូច**

| លរ | ឈ្មោះ កសិករ | ភេទ | អាយុ/ ឆ្នាំ | សមាជិកក្នុង បន្ទុក(នាក់) | ប្រភព និងប្រាក់ ចំណូល | កម្មសិទ្ធិដី (ហត) | ដីជួលគេ/ ជួលឲ្យ គេ (ហត) | ផ្ទៃដីដាំ ដុះសរុប (ហត) | ផ្ទៃដីដាំ ដុះស្រូវ (ហត) | ផ្ទៃដីដាំ ដុះដំណាំ (ហត) | ទិន្នផល ស្រូវ | ចំនួនគោ/ ក្របី | ចំនួន ជ្រូក | ចំនួន មាន់ | ចំនួន ទា | ចំនួន ខែខ្វះ ស្បៀង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

តារាង ៣.៣. ឈ្មោះក្រុមកសិករសិក្សាខ្នាតតូច

| លរ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះ កសិករ | តួនាទីក្នុងក្រុម | លេខសំគាល់ កសិករ | ភេទ | ឆ្នាំ កំណើត | ជនជាតិ ភាគតិច | ស្ថានភាពគ្រួសារ | | | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | ក្រ១ | ក្រ២ | មធ្យម | |
| ១ | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | | |
| ១៦ | | | | | | | | | | | | | | |
| ១៧ | | | | | | | | | | | | | | |
| ១៨ | | | | | | | | | | | | | | |

| លរ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះ កសិករ | តួនាទីក្នុងក្រុម | លេខសំគាល់ កសិករ | ភេទ | ឆ្នាំ កំណើត | ជនជាតិ ភាគតិច | ស្ថានភាពគ្រួសារ | | | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | ក្រ១ | ក្រ២ | មធ្យម | |
| ១៩ | | | | | | | | | | | | | | |
| ២០ | | | | | | | | | | | | | | |
| ២១ | | | | | | | | | | | | | | |
| ២២ | | | | | | | | | | | | | | |
| ២៣ | | | | | | | | | | | | | | |
| ២៤ | | | | | | | | | | | | | | |
| ២៥ | | | | | | | | | | | | | | |
| | សរុប | | | | | | | | | | | | | |

# ជំហានទី ៤: ការរៀបចំរចនាសម្ព័ន្ធក្រុម លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង កសិករសិក្សាខ្នាតតូច

**គោលបំណង ៖**

- ដើម្បីរៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង និងដំណើរការសកម្មភាពរបស់ក្រុមកសិករសិក្សាខ្នាតតូច
- ដើម្បីពិភាក្សា និងបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមអនុវត្ត លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច

**លទ្ធផលរំពឹងទុក ៖**

- បានរៀបចំក្រុមកសិករសិក្សាខ្នាតតូចដើម្បីចូលរួមដំណើរការអនុវត្តកម្មវិធី ឬគម្រោង (ឧ.កម្មវិធី ASPIRE) ប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងនិរន្តរភាព។

**អ្នកចូលរួម** :

- កសិករដែលបានជ្រើសរើស ពី២៥ ទៅ៣0នាក់ និងមានការចូលរួមគាំទ្រពី អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ ឬ គណៈកម្មការទទួលបន្ទុក ស្ត្រី និងកុមារឃុំ (CWCC) និងមន្ត្រីផ្សព្វផ្សាយ ខេត្ត ស្រុកនិងភ្នាក់ងារផ្សព្វផ្សាយឃុំ។

**សម្ភារ** :

- ក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្រដាស ស្កុត កន្ត្រៃ សៀវភៅសរសេរ និងប៊ិច។

**រយៈពេល**: ២ ម៉ោង

**ទីកន្លែង**: ក្នុងភូមិ

**អ្នកសម្របសម្រួល**: មន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ។

**ដំណើរការអនុវត្ត**:

- ការពិភាក្សា និងរៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច
- ការពិភាក្សា និងបោះឆ្នោតជ្រើសរើសអ្នកដឹកនាំក្រុមកសិករសិក្សាខ្នាតតូច

**ឧទា. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូចគំរូ**

# លក្ខន្តិកៈរបស់ក្រុមកសិករសិក្សាខ្នាតតូច
# ជំពូកទី១
# អត្តសញ្ញាណ នីត្យានុកូលភាព និងកម្មវត្ថុមុខជំនួញ

**ប្រការ១**.

ក្រុមកសិករសិក្សាខ្នាតតូចនេះមានអត្តសញ្ញាណដូចខាងក្រោម៖

១.ឈ្មោះ៖ **ក្រុមកសិករសិក្សាខ្នាតតូច**

សរសេរជាអក្សរកាត់៖

ឈ្មោះជាភាសាអង់គ្លេស៖ Smallholder Learning Group

សរសេរជាអក្សរកាត់៖ SLG

២.អាស័យដ្ឋានទីស្នាក់ការ៖ ផ្ទះលេខ...............ផ្លូវលេខ.............ភូមិ................

ឃុំ/សង្កាត់..................................ក្រុង/ស្រុក/ខណ្ឌ...................រាជធានី/ខេត្ត..............

**ប្រការ២**.

ក្រុមកសិករសិក្សាខ្នាតតូចបំពេញការងារជូនសមាជិក សមាជិកាដូចខាងក្រោមៈ

១. ធានាសិទ្ធិរបស់សមាជិក សមាជិកាក្នុងការចូលរួមបំពេញគោលដៅសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយធ្វើជាតំណាងឲ្យសមាជិក ដើម្បីចុះកិច្ចសន្យានិងអនុវត្តកិច្ចសន្យាជាមួយផ្នែកឯកជន ឬដៃគូអភិវឌ្ឍផ្សេងទៀត។

២. សម្រួលការចូលរួមសកម្មភាពរបស់សមាជិក សមាជិកានៅក្នុងការស្ថាបនា និងអភិវឌ្ឍន៍ក្រុមកសិករសិក្សាខ្នាតតូច ឬ សហគមន៍កសិកម្ម តាមរយៈការលើកកម្ពស់សមត្ថភាពរបស់សមាជិក ដោយផ្តល់នូវសេវាកម្មគាំទ្រផលិតកម្មកសិកម្ម ផ្តល់ជំនួយបច្ចេកទេស ផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាល ផ្តល់ព័ត៌មានពាក់ព័ន្ធទាំងឡាយ អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងនាំមកនូវបច្ចេកវិទ្យាថ្មី និងទំនើបនៅក្នុងផលិតកម្មកសិកម្ម ដើម្បីទទួលបានទិន្នផលខ្ពស់ទាំងបរិមាណ និងគុណភាព ដោយធានាបាននូវ ស្ថិរភាពទីផ្សារនិងថ្លៃផលិតផល ព្រមទាំងមានតម្លៃបន្ថែមចំពោះផលិតផលសម្រាប់ការប្រកួតប្រជែងទីផ្សារប្រកបដោតតម្លាភាព និងប្រសិទ្ធភាព។

៣. ស្នើសុំ ឬទទួលយកជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភីវឌ្ឍន៍ និងពីប្រភពជំនួយស្របច្បាប់ផ្សេងទៀត។

៤. បំពេញបេសកកម្មពាក់ព័ន្ធផ្សេងទៀត សម្របតាមដំណាក់កាលរីចម្រើនរបស់ខ្លួនក្រោមគោលដៅអភិវឌ្ឍក្រុមកសិករសិក្សាខ្នាតតូច។

**ប្រការ៣**.

**ក្រុមកសិករសិក្សាខ្នាតតូច ក្នុងទិសដៅរយៈពេលខ្លី និងរយៈពេលវែងធ្វើប្រតិបត្តិការមុខរបរដូចខាងក្រោម៖**

**ក- ផលិតកម្មកសិកម្ម**

១...........................................................................................................................................

**ខ- កសិឧស្សាហកម្ម**

១...........................................................................................................................................

**គ- កសិពាណិជ្ជកម្ម**

១...........................................................................................................................................

**ឃ- សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម**

១...........................................................................................................................................

## ជំពូកទី២
## ការលាឈប់ និងការបញ្ឈប់សមាជិកភាពក្រុមកសិករសិក្សាខ្នាតតូច

**ប្រការ៤.**

សមាជិកភាពរបស់ក្រុមកសិករសិក្សាខ្នាតតូចត្រូវបាត់បង់ ដោយអនុលោមតាមករណីមួយចំនួនដូចខាងក្រោម៖

- ការសុំលាឈប់ពីសមាជិកភាពក្រុមកសិករសិក្សាខ្នាតតូចដោយស្ម័គ្រចិត្ត
- ការផ្ទេរសិទ្ធ អត្ថប្រយោជន៍ និងតួនាទីទៅសមាជិកផ្សេងទៀតដោយអនុលោមតាមសេចក្តីសម្រេចនៃអង្គប្រជុំ
- ការរំលោពបំពានសេចក្តីសម្រេចរបស់អង្គប្រជុំ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទបញ្ញាតិនានារបស់ក្រុមកសិករសិក្សាខ្នាតតូច
- ការរំលោយ ឬមិនមានលក្ខណៈសម្បត្តិពេញលេញដោយអនុលាមតាមលក្ខន្តិកៈ
- ការបណ្តេញចេញ ដោយមូលហេតុរំលោភបំពានធ្ងន់ធ្ងរលើលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងដែលត្រូវសម្រេចដោយអង្គប្រជុំតាមសម្លេង ២/៣ (ពីរភាគបី)។

**ប្រការ៥.**

សមាជិក សមាជិកាក្រុមកសិករសិក្សាខ្នាតតូច មានសិទ្ធសុំលាឈប់ពីសមាជិកភាពក្រុមកសិករសិក្សាខ្នាតតូចបាន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅ ប្រធានក្រុម ក្នុងរយៈពេលមិនតិចជាង១(មួយ) ខែ ។ ប្រធានក្រុមត្រូវពិនិត្យករណីស្នើសុំលាឈប់ពីសមាជិកភាពក្រុមកសិករសិក្សាខ្នាតតូចដោយធ្វើរបាយការណ៍ដាក់ក្នុងអង្គប្រជុំដើម្បីអនុម័ត។

**ប្រការ៦.**

ក្នុងករណីសមាជិក សមាជិកាក្រុមកសិករសិក្សាខ្នាតតូច បំពានធ្ងន់ធ្ង លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទបញ្ញាតិនានារបស់ក្រុមកសិករសិក្សាខ្នាតតូច ប្រធានក្រុមត្រូវធ្វើរបាយការណ៍កំហុសឆ្គងរបស់សមាជិកនោះ ដាក់ចូលក្នុងអង្គប្រជុំសម្រេច។

សមាជិករូបនោះអាចត្រូវបញ្ចប់ពីសមាជិក ក្រុមកសិករសិក្សាខ្នាតតូចក្នុងករណីអង្គប្រជុំសម្រេចចេញតាមសម្លេង២/៣ (ពីរភាគបី)។

## ជំពូកទី៣
## រចនាសម្ព័ន្ធគ្រប់គ្រងក្រុមកសិករសិក្សាខ្នាតតូច

**ប្រការ៧.**

ក្រុមកសិករសិក្សាខ្នាតតូចមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១. ប្រធាន។

២. អនុប្រធាន។

៣. លេខាធិការ។

**ប្រការ៨.**

ប្រធាន អនុប្រធាន និងលេខាធិការត្រូវ ជ្រើសរើសចេញពីការបោះឆ្នោត ។ ជាអ្នកអាចចេះសរសេរ និងអានបាន មានភាពស្មោះត្រង់ ចំពោះក្រុម និងមានគំនិតផ្តួចផ្តើមក្នុងការដឹកនាំ ។

## ផ្នែកទី១
## ប្រធាន

**ប្រការ៩**.

ប្រធានគឺជាបុគ្គលខ្ពស់បំផុតរបស់ក្រុមកសិករសិក្សាខ្នាតតូច ដែលមានសិទ្ធអំណាចធ្វើការអនុម័តលើកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងនៅក្នុងដំណើរការបង្កើត ការប្រព្រឹត្តទៅ និងការអភិវឌ្ឍរបស់ក្រុមកសិករសិក្សាខ្នាតតូច។

**ប្រការ១០**.

ប្រធានមានសិទ្ធដឹកនាំក្រុមកសិករសិក្សាខ្នាតតូច ឲ្យចូលរួមសកម្មភាពកម្មវិធី ឬគម្រោង ដូចជាកម្មវិធី ASPIRE (សាលារៀនស្រែកសិករ ការធ្វើបង្ហាញ ទិវាបង្ហាញ វេទិកាផ្សេងៗ ផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ និងកសិករ) ដើម្បីអាចទទួលបាននូវផលិតភាព គុណភាព សុវត្ថិភាព ផលិតផលកសិកម្ម បង្កើនប្រាក់ចំណូល និងជីវភាពរស់នៅ ព្រមទាំងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ប្រធានត្រូវទទួលខុសត្រូវរួមចំពោះសមាជិកក្រុមទាំងមូល និងសម្របសម្រួល ដោះស្រាយរាល់បញ្ហាដែលកើតមានឡើង គោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច។

**ប្រការ១១**.

ប្រធានមានភារកិច្ចរៀបចំផែនការប្រជុំប្រចាំខែ ឬប្រចាំឆ្នាំ ឬកោះប្រជុំបន្ទាន់ណាមួយចាំបាច់។

## ផ្នែកទី២
## អនុប្រធាន

**ប្រការ១២**.

អនុប្រធានគឺជាជំនួយការរបស់ប្រធានក្រុមកសិករសិក្សាខ្នាតតូច ជំនួសមុខឲ្យប្រធានក្នុងករណីប្រធានអវត្តមាន និងអនុវត្តន៍ទៅតាមការចាត់តាំង ឬការណែនាំពីប្រធាន អនុប្រធានត្រូវតែគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច។

## ផ្នែកទី៣
## លេខាធិការ

**ប្រការ១៣**.

លេខាធិការគឺជាជំនួយការរបស់ប្រធាន និងអនុប្រធាន ជាអ្នករក្សា និងកត់ត្រា នូវរាល់ទិន្នន័យផ្សេងៗរបស់ក្រុម រក្សាទុកនូវរាល់ឯកសារទាំងឡាយដែលពាក់ពន្ធ័ និងអនុវត្តន៍ទៅតាមការណែនាំរបស់ប្រធានក្រុមលេខាធិការត្រូវតែគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមកសិករសិក្សាខ្នាតតូច។

## ជំពូកទី៤
## ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិក្រុមកសិករខ្នាតតូច

## ផ្នែកទី១
## ដើមទុន និងមូលនិធិ

**ប្រការ១៤.**

ប្រភពដើមទុនរបស់ក្រុមកសិករសិក្សាខ្នាតតូចបានមកពីៈ

- ការបង់ដោយសមាជិក សមាជិកា ជាប្រាក់សន្សំ
- អំណោយ ឬវិភាគទានដែលត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិរបស់ក្រុមកសិករសិក្សាខ្នាតតូច ត្រូវរក្សាទុកក្នុងគណនីដោយឡែក
- ជំនួយឥតសំណង ឬកម្ចីឥណទាន ឬមូលនិធិប្រភពផ្សេងៗ។

**ប្រការ១៥.**

ក្រុមកសិករសិក្សាខ្នាតតូច ត្រូវគ្រប់គ្រងថវិកា ឬសាច់ប្រាក់របស់ខ្លួន តាមរយៈការរក្សាទុកក្នុងគណនីនៃធនាគារ ............ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៦.**

ក្រុមកសិករសិក្សាខ្នាតតូច ត្រូវបង្កើត គ្រប់គ្រង និងប្រើប្រាស់មូលនិធិរបស់ខ្លួន ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គប្រជុំ។

រាល់ការចំណាយ និងចំណូលទាំងឡាយដែលបម្រើឲ្យផលប្រយោជន៍ក្រុមត្រូវតែមានគណនេយ្យភាព និងតម្លាភាព។

## ផ្នែកទី១
## ទ្រព្យសម្បត្តិ

**ប្រការ១៧.**

ទ្រព្យសម្បត្តិរបស់ក្រុមកសិករសិក្សាខ្នាតតូច បង្កើតបានជាដើមទុនសកម្មរបស់ក្រុមកសិករសិក្សាខ្នាតតូច។ ទ្រព្យសម្បត្តិទាំងនោះរួមមានៈ ថវិកា ដីធ្លី អាគារគ្រប់ប្រភេទ ចលនវត្ថុគ្រប់ប្រភេទ មធ្យោបាយ សម្ភារបរិក្ខាគ្រប់ប្រភេទ វិភាគទាន អំណោយគ្រប់រូបភាព និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលបង្កើតឡើងដោយក្រុមកសិករសិក្សាខ្នាតតូច។

**ប្រការ១៨.**

នៅពេលក្រុមកសិករសិក្សាខ្នាតតូចត្រូវរំលាយ ការកាន់កាប់ទ្រព្យសម្បត្តិ និងមូលនិធិរបស់ក្រុម ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមៈ

១. ប្រគល់ជូនស្ថាប័ន ឬអង្គភាពដើមដែលបានឧបត្ថម្ភទ្រព្យសម្បត្តិនោះ

២. ទ្រព្យសម្បត្តិដែលបានមកពីការរួមចំណែករបស់សមាជិក សមាជិកានៃក្រុមកសិករសិក្សាខ្នាតតូចត្រូវសម្រេចតាមរយៈអង្គប្រជុំ។

## ផ្នែកទី២
## ប្រាក់ចំណេញ

**ប្រការ១៩.**

ក្រោយខ្ទង់ចំណាយផ្សេងៗ ប្រាក់ចំណេញសុទ្ធរបស់ក្រុមកសិករសិក្សាខ្នាតតូច អាចបែងចែកក្នុងកម្រិតសមស្របសម្រាប់៖

១. មូលនិធិបម្រុង ក្នុងកម្រិត ២០%។

២. មូលនិធិបណ្តុះបណ្តាល ក្នុងកម្រិត ៣%។

៣. មូលនិធិលើកទឹកចិត្ត ក្នុងកម្រិត............% សម្រាប់បែងចែកដល់សមាជិក សមាជិកា ដោយសមាមាត្រទៅក្នុងសកម្មភាពរបស់សមាជិកជាមួយនឹងក្រុមកសិករសិក្សាខ្នាតតូច។

៤. មូលនិធិរង្វាន់ សរសើរ និងសុខមាលភាព ក្នុងកម្រិត................%សម្រាប់ផ្តល់ដល់សមាជិក សមាជិកាដែលបានបង្កើតស្នាដៃផ្តើម និងសម្រាប់ឧត្តម្ភដល់សមាជិក សមាជិកាដែលជួបគ្រោះអាសន្នចាំបាច់។

## ជំពូកទី៥
## វិវាទ និងការដោះស្រាយវិវាទ

**ប្រការ១៩.**

វិវាទនៅក្នុងក្រុមកសិករសិក្សាខ្នាតតូច ត្រូវបានដោះស្រាយដូចខាងក្រោម៖

១. វិវាទរវាងសមាជិក ជាមួយនឹងសមាជិក និងវិវាទរវាងសមាជិកជាមួយក្រុមកសិករខ្នាតតូច ត្រូវដោះស្រាយជាបឋមក្នុងកិច្ចប្រជុំ។

២. វិវាទរវាងក្រុមកសិករសិក្សាខ្នាតតូចជាមួយ ក្រុមកសិករសិក្សាខ្នាតតូចដ៏ទៃទៀត ត្រូវដោះស្រាយដោយមានការចូលរួមពីអគ្គនាយកដ្ឋានកសិកម្ម ។

៣. វិវាទក្នុងក្រុមកសិករសិក្សាខ្នាតតូចដែលមិនអាចដោះស្រាយបានដោយ អគ្គនាយកដ្ឋានកសិកម្ម ក្នុងនាមជាស្ថាប័នអាណាព្យាបាល ឬអាជ្ញាកណ្តាល នោះភាគីនោះត្រូវធ្វើពាក្យបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធ ឬធ្វើពាក្យបណ្តឹងទៅតុលាការនៅក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចរបស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដើម្បីវិនិច្ឆ័យតាមនីតិវិធីតុលាការ។

## ជំពូកទី៦
## ការកែប្រែ ឬវិសោធនកម្ម

**ប្រការ២០.**

លក្ខន្តិកៈអាចឬកែប្រែ ធ្វើវិសោធនកម្មបានដោយការប្រជុំក្នុងក្រុមកសិករសិក្សាខ្នាតតូចតាមសម្លេង ២/៣ (ពីរភាគបី) នៃសមាជិកវត្តមានក្នុងកិច្ចប្រជុំ។

ក្នុងករណីក្រុមកសិករសិក្សាខ្នាតតូចកែប្រែនាមករណ៍របស់ខ្លួននៅក្នុងលក្ខន្តិកៈ ក្រុមកសិករសិក្សាខ្នាតតូចត្រូវស្នើសុំមកមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**ប្រការ២១**.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២**.

លក្ខន្តិកៈនេះត្រូវបានអនុម័តដោយសមាជិកក្រុមកសិករសិក្សាខ្នាតតូច តាមសម្លេងគាំទ្រចំនួន..........លើ........នៅក្នុងសម័យប្រជុំក្រុមកសិករសិក្សាខ្នាតតូចលើកទី......នាថ្ងៃទី............ខែ.................ឆ្នាំ..............លក្ខន្តិកៈនេះត្រូវផ្ញើជូនសមាជិកក្រុមកសិករសិក្សាខ្នាតតូច ដើម្បីទទួលខុសត្រូវចាប់ពីការបរិច្ឆេទចុះបញ្ជីក្រុមកសិករសិក្សាខ្នាតតូចនេះតទៅ។

ធ្វើនៅភូមិ..............ថ្ងៃទី.........ខែ.......ឆ្នាំ២០....

**ហត្ថលេខា ឬស្នាមមេដៃ ប្រធានក្រុម**

ឈ្មោះ.................................

ថ្ងៃទី..........ខែ.......ឆ្នាំ២០......

............................................

**ហត្ថលេខា និងត្រាឃុំ (សាក្សី)**

ថ្ងៃទី..........ខែ.......ឆ្នាំ២០១......

ភូមិ.......................................

**ហត្ថលេខាមេភូមិ (សាក្សី)**

# បទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមកសិករសិក្សាខ្នាតតូច
## ជំពូកទី១
## គោលបំណង និងវិសាលភាព

**ប្រការ១**.

បទបញ្ជាផ្ទៃក្នុងនេះមានគោលបំណងធានាតម្លាភាព គណនេយ្យភាព ភាពស្មោះត្រង់ ទំនុកចិត្ត យុត្តិធម៌ សាមគ្គីភាព ផ្ទៃក្នុងនិងប្រសិទ្ធភាពការងារ នៅក្នុងដំណើរការគ្រប់គ្រងក្រុមកសិករខ្នាតតូច ជួយស្ថាបនា និងអភិវឌ្ឍ ក្រុមកសិករខ្នាតតូច ស្របតាមលក្ខខណ្ឌសង្គមសេដ្ឋកិច្ច និងគោលការណ៍របស់ក្រុម។

**ប្រការ២**.

បទបញ្ជាផ្ទៃក្នុងនេះមានវិសាលភាពអនុវត្តក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធ ការដឹកនាំ ការគ្រប់គ្រង និងការប្រតិបត្តិ មុខជំនួញរបស់ក្រុមកសិករសិក្សាខ្នាតតូច។

## ជំពូកទី២
## កិច្ចការដែលត្រូវអនុវត្ត

**ប្រការ៣**.-

១.សមាជិកម្នាក់ៗនឹងចូលរួមការប្រជុំក្រុមប្រចាំខែជាទៀងទាត់ ដោយការណែនាំរបស់អ្នកសម្របសម្រួល/មន្ត្រី ឬភ្នាក់ងារផ្សព្វផ្សាយ រាប់បញ្ចូលទាំងព្រឹត្តិការណ៍បណ្តុះបណ្តាល ដំណើរការដោះស្រាយបញ្ហារបស់ក្រុមការផ្លាស់ ប្តូរបទពិសោធន៍ និងគំនិតផ្សេងៗ ។

២.សមាជិកម្នាក់ៗត្រូវតែស្ម័គ្រចិត្តទទួលធ្វើបង្ហាញនៅក្នុងកសិដ្ឋានរបស់គេ ក្នុងការរៀបចំ ដើម្បីអនុវត្តន៍ចំណេះ ដឹងនឹងជំនាញថ្មីៗរបស់គេដែលបានណែនាំដោយក្រុមអ្នកសម្របសម្រួល/មន្ត្រីឬភ្នាក់ងារផ្សព្វផ្សាយដោយការលើក យក គោលការណ៍សំខាន់ ការសម្រេចតាមបែបចូលរួម។

៣. សមាជិកម្នាក់ៗ ត្រូវតែស្ម័គ្រចិត្តចូលរួមនូវជំនាញ ចំណេះដឹង នឹងបទពិសោធន៍របស់គេ ជាមួយសមាជិក ក្រុមផ្សេងៗទៀត ដូចជាផ្នែកមួយនៃសកម្មភាពដែលបានរៀបចំ ក្នុងទិវាបង្ហាញ(ទស្សនៈកិច្ចសិក្សាកសិដ្ឋាន កសិករ ជិតៗខាង ទិវាបង្ហាញ កម្មវិធីការប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗទៀត)។

៤.សមាជិកម្នាក់ៗ ត្រូវតែរក្សា និងកត់ត្រានូវសកម្មភាពរបស់គេ នឹងធ្វើរបាយការណ៍នេះជូនទៅប្រធានក្រុម (មានទាំងការដាក់បញ្ចូលនូវការអនុវត្តផ្ទាល់នូវរបរកសិកម្មថ្មីៗ និងប្រាក់ចំណេញពីការទទួលយកនិងអនុវត្តន៍បច្ចេក ទេស កសិកម្មថ្មីៗ) បន្ថែមទៀតគឺការចូលរួម ក្នុងការតាមដាន និងការងារអង្កេតផ្សេងៗទៀត។

៥.សមាជិកក្រុមត្រូវតែសកម្មក្នុងការគាំទ្រ និងលើកទឹកចិត្តដល់កសិករផ្សេងៗទៀត ដើម្បីអនុវត្តផ្ទាល់នូវរបរ កសិកម្មថ្មីៗ ដែលខ្លួនគេបានអនុវត្តផ្ទាល់ នឹងទទួលបានជោគជ័យ។

## ជំពូកទី៣
## វិន័យនិងទណ្ឌកម្ម

**ប្រការ៤**.-

រាល់សកម្មភាពទាំងឡាយណាដែលផ្ទុយពីប្រការ២ ត្រូវដាក់ពិន័យ និងទណ្ឌកម្មដូចខាងក្រោមៈ

លើកទី១ៈ ត្រូវធ្វើការណែនាំ និងចុះកិច្ចសន្យា

លើកទី២ៈ ត្រូវដាក់ពិន័យ.................

លើកទី៣៖ ករណីនៅតែប្រព្រឹត្តប្រធានក្រុមសិក្សាខ្នាតតូចត្រូវប្រជុំសម្រេចលប់ឈ្មោះចេញពីសមាជិកភាពនៃក្រុមកសិករសិក្សាខ្នាតតូច។

ថ្ងៃទី..........ខែ.......ឆ្នាំ២០១......
ភូមិ.......................................
**ហត្ថលេខាមេភូមិ (សាក្សី)**

ថ្ងៃទី..........ខែ.......ឆ្នាំ២០......

.............................................
**ហត្ថលេខា និងត្រាឃុំ (សាក្សី)**

ធ្វើនៅភូមិ...............ថ្ងៃទី.........ខែ.......ឆ្នាំ២០...
**ហត្ថលេខា ឬស្នាមមេដៃ ប្រធានក្រុម**

ឈ្មោះ.................................

**កំណត់ចំណាំ:**

គម្រូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះបានអនុឡោមតាម ប្រកាសស្តីពី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគម្រូសម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិករកម្ពុជា។

ទម្រង់នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង គឺ៖

- ត្រូវរៀបចំឡើងតាមរយៈការប្រជុំក្រោយពីក្រុមត្រូវបានចងក្រងរួចហើយ
- ផ្អែកតាមប្រភេទក្រុមនីមួយៗ (ចក្ខុវិស័យ គោលបំណង និងគោលដៅរបស់ក្រុម)

# ជំហានទី ៥: យន្តការស្មារតីរបស់ក្រុមកសិករសិក្សាខ្នាតតូច

**គោលបំណង ៖**

- ជម្រុញការយកចិត្តទុកដាក់ និងលើកកំពស់វប្បធម៌ ផ្ទេរបន្ត សមិទ្ធិផលរបស់ក្រុមនិងជួយសមាជិកក្រុមក្នុងការបង្កើត ឬពង្រីកមុខរបរ ព្រមទាំងបច្ចេកទេស។

**លទ្ធផលរំពឹងទុក ៖**

- ក្រុមកសិករសិក្សាខ្នាតតូចទទួលបាននូវទំនុកចិត្តពីការចែករំលែកចំណេះដឹង និងផ្ទេរបន្តសមិទ្ធិផលពីកម្មវិធី ឬគម្រោង។

**អ្នកចូលរួម** :

- កសិករដែលបានជ្រើសរើស ពី២៥ ទៅ៣០នាក់ និងមានការចូលរួមគាំទ្រពី អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ ឬគណៈកម្មការទទួលបន្ទុក ស្ត្រី និងកុមារឃុំ (CWCC) និងមន្ត្រីផ្សព្វផ្សាយ ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ។

**សម្ភារ** :

- ក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្រដាស ស្កុត កន្ត្រៃ សៀវភៅសរសេរ និងប៊ិច

**រយៈពេល**: ៣០ នាទី

**ទីកន្លែង**: ក្នុងភូមិ

**អ្នកសម្របសម្រួល**: មន្ត្រីផ្សព្វផ្សាយកសិកម្ម ខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ

**ដំណើរការអនុវត្ត**:

ការពិភាក្សា ការបង្កើតនូវ " **<u>យន្តការស្មារតីរបស់ក្រុម</u>**" គឺត្រូវយកចិត្តទុកដាក់និងលើកកំពស់ វប្បធម៌ចែលរំលែក និងផ្ទេរបន្ត សមិទ្ធិផលរបស់ក្រុមព្រមទាំងបច្ចេកទេសដូចជា៖

**១. កសិករធ្វើបង្ហាញដំណាំផ្សេងៗ ឬការចិញ្ចឹមសត្វ**

- ជួយបង្ហាត់បង្ហាញបច្ចេកទេសនៃការធ្វើបង្ហាញ (ដំណាំបន្លែ ស្រូវ ការចិញ្ចឹមមាន់ ជ្រូកដំណាំចម្រុះផ្សេងៗ ដល់កសិករដទៃទៀតក្នុងក្រុម។
- ចូលរួមចំណែកជាសម្ភារៈ និងថវិកាដើម្បីបង្កើតកសិដ្ឋានបង្ហាញ។
- ចុះកិច្ចសន្យា ការធ្វើបង្ហាញជាមួយ មន្ត្រីផ្សព្វផ្សាយ និងភ្នាក់ងារផ្សព្វផ្សាយឃុំដោយមានប្រធានភូមិក្រុមប្រឹក្សាឃុំចូលរួមផ្តល់ជាសាក្សី ដូចជា៖
  - រាយការណ៍ពីសត្វឈឺឬងាប់ ឬដំណាំជួបប្រទះជម្ងឺ មកកាន់គ្រូបណ្តុះបណ្តាល
  - ផ្តល់ដល់មេក្រុម៖
    - បើចិញ្ចឹមជ្រូកត្រូវ ផ្តល់កូនជ្រូកផ្តាច់ដោះ១ក្បាល
    - បើចិញ្ចឹមមាន់ត្រូវផ្តល់កូនមាន់ ជំទង់ ទម្ងន់ ១គីឡូក្រាម ចំនួន១០ក្បាល
    - បើស្រូវត្រូវផ្តល់ពូជស្រូវ ចំនួន ១០គីឡូក្រាម
    - បើបន្លែត្រូវផ្តល់ពូជបន្លែ ចំនួន ០,៥ គីឡូក្រាម

ដើម្បីមេក្រុមចាត់ចែងប្រជុំសមាជិកក្រុម និងធ្វើការបោះឆ្នោតផ្តល់បន្តដល់សមាជិកក្រុមដែលក្រីក្រប៉ុន្តែមានគំនិតផ្តួចផ្តើមក្នុងការប្រកបរបរកសិកម្ម។

- សហការណ៍ជាមួយមន្ត្រីផ្សព្វផ្សាយស្រុក និងអ្នកផ្សព្វផ្សាយឃុំ ក្នុងការសម្របសម្រួលទិវាបង្ហាញ នឹងដឹកនាំទិវាបង្ហាញដល់កសិករក្នុងភូមិ
- ណែនាំបច្ចេកទេសបន្តដល់សមាជិកក្រុមដែលមានបំណងសាកសួរនូវបច្ចេកទេសថ្មី

**២. វគ្គបណ្តុះបណ្តាល**

- បន្ទាប់ពីវគ្គបណ្តុះបណ្តាលបច្ចេកទេស កសិករដែលមានដី ឬមានលទ្ធភាពទិញជាពូជដំណាំ ឬពូជសត្វ អាចចែលរំលែកៈ
  - ទីកន្លែងសម្រាប់ការ ដាំដំណាំផ្សេងៗ ឬ ការចិញ្ចឹមសត្វជាមួយកសិករដែលមិនមានដី (កសិករដែលងាយរងគ្រោះជាងគេនៅក្នុងក្រុម)
  - ដើម្បីគេមានលទ្ធភាពអនុវត្តនូវបច្ចេកទេសថ្មីដែលទើបទទួលបានពីកម្មវិធី (តាមរយៈការជួល ដី ឬចិញ្ចឹមមេជ្រូកប្រវ៉ាស់) ទទួលបានប្រាក់ចំណូល និងដើម្បីឆ្លើយតប និងភាពធន់ទ្រាំនៃជីវភាពរស់នៅរបស់គេ។

**៣. ការងារទំនាក់ទំនង**

- មានទំនាក់ទំនងល្អជាមួយ មន្ត្រីផ្សព្វផ្សាយ និងភ្នាក់ងារផ្សព្វផ្សាយឃុំ ក្នុងគោលបំណងចែករំលែក បទពិសោធន៍ បញ្ហាប្រឈម និងបញ្ហានានាដែលកើតមានក្នុងក្រុម និងដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធ ក្នុងការដាំដុះ និងចិញ្ចឹមសត្វទាន់ពេលវេលា។